# ឧបសម្ព័ន្ធ

# ការវិភាគលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងមូលដ្ឋាន ១ នៃបណ្តឹងឧទ្ធរណ៍

| ល.រ | ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី | សំអាងហេតុចៅក្រមអន្តរជាតិពាក់ព័ន្ធនឹងការចោទប្រកាន់អំពីកំហុស របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ | សេចក្តីពិចារណាលើ ភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី |
|---|---|---|---|
| ១. | 14-VSS-00014<br>D11/383<br>**ហេង ណាវី** | នៅក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ (VIF) ចុះកាលបរិច្ឆេទឆ្នាំ២០០៩ អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា ឪពុក និងជីដូនជីតារបស់គាត់បានស្លាប់ដោយសារការអត់ឃ្លាននៅខេត្តកំពតក្នុងឆ្នាំ១៩៧៦ ឪពុកមា ម្តាយមីង និងបងប្អូនជីដូនមួយត្រូវបានសម្លាប់នៅខេត្តកំពត ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងទម្រង់បែបបទស្តីពីព័ត៌មានបន្ថែមចុះកាលបរិច្ឆេទឆ្នាំ២០១៣ អ្នកដាក់ពាក្យសុំបានលើកឡើងថា ជីដូនជីតា ឪពុក បងប្អូនជីដូនមួយ ឪពុកមា និងម្តាយមីងរបស់គាត់ត្រូវបានគេយកទៅសម្លាប់ចោលនៅមន្ទីរសន្តិសុខ ចំការធូរ៉េន នៅស្រុកព្រៃនប់ ខេត្តកំពង់សោម ក្នុងឆ្នាំ១៩៧៨។ | ពាក្យសុំ **មិនអាចទទួលយកបានទេ។** សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន **តម្កល់ទុកជាបានការ។** |

| | | | |
|---|---|---|---|
| | | ដោយសារភាពមិនស៊ីសង្វាក់គ្នាខ្លាំងដូចបានកត់សម្គាល់រវាង ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ និងទម្រង់បែបបទព័ត៌មានបន្ថែម រួមទាំង ទីតាំងផ្សេងៗគ្នា (ខេត្តមួយផ្សេង) កាលបរិច្ឆេទ និងមូលហេតុនៃមរណភាពរបស់ឪពុក ជីដូនជីតា និងបងប្អូនជីដូនមួយរបស់គាត់ ចៅក្រមអន្តរជាតិយល់ឃើញថា អ្នកដាក់ពាក្យសុំមិនបានបង្ហាញថា វាមានភាពពិតប្រាកដ ដែលគាត់បានទទួលការឈឺចាប់ដែលជាផលវិបាកនៃឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មជាច្រើន ដែលត្រូវបានចោទប្រកាន់។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសដោយសារការបដិសេធពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះឡើយ។ | |
| ២. | 11-VSS-00301<br>D11/86<br>**គង់ សំណាង** | អ្នកដាក់ពាក្យសុំ បានពិពណ៌នាថាត្រូវបានជម្លៀសដោយបង្ខំជាមួយគ្រួសាររបស់គាត់ពីកម្ពុជាក្រោមទៅស្រុកគិរីវង់ ខេត្តតាកែវ ក្នុងឆ្នាំ១៩៧៨ ត្រូវបានគេបង្ខំឱ្យធ្វើការធ្ងន់ធ្ងរ បង្អត់អាហារ និងផ្តល់ការថែទាំសុខភាពមិនគ្រប់គ្រាន់នៅស្រុកគីរីវង់ពីឆ្នាំ១៩៧៨ ដល់ ឆ្នាំ១៩៧៩ មរណភាពរបស់ម្តាយ និងជីតារបស់គាត់ ដោយសារការងារបាក់កម្លាំង ការអត់ឃ្លាន និងជំងឺនៅក្នុងឆ្នាំ១៩៧៨ នៅស្រុកគិរីវង់ ឃាតកម្មលើឪពុកមារបស់គាត់នៅស្រុកអង្គរជ័យ ខេត្តកំពត ក្រោមការចោទប្រកាន់ថាជាជនជាតិវៀតណាមនៅចុងឆ្នាំ១៩៧៨ និងការជម្លៀសដោយបង្ខំចំពោះគ្រួសាររបស់ឪពុកមាគាត់ម្នាក់ទៀត (ដែលត្រូវបានគេចោទប្រកាន់ថាជាទាហានលន់ណុល) ទៅវាលរេញ ស្រុកព្រៃនប់ ខេត្តកំពង់សោម | ពាក្យសុំត្រូវបាន**ទទួលយក**។ សេចក្តីសម្រេច របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន **ច្រានចោល**។ |

| | | | |
|---|---|---|---|
| | | និងការប្រហារជីវិតជាបន្តបន្ទាប់នៅឆ្នាំ១៩៧៧ នៅភ្នំបូកគោ ខេត្តកំពត បន្ទាប់ពីបានរកឃើញប្រវត្តិរូបរបស់គាត់។<br><br>ឪពុកមា និងគ្រួសាររបស់អ្នកដាក់ពាក្យសុំ ត្រូវបានជម្លៀសទៅកាន់វាលរេញ ខេត្តកំពង់សោម ដែលវាមានភាពពិតប្រាកដដែលថា គាត់បានទទួលការឈឺចាប់ដែលជាផលវិបាកនៃឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មជាច្រើន ដែលត្រូវបានចោទប្រកាន់ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដោយសារបានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារព្រឹត្តិការណ៍ទាំងនេះស្ថិតនៅក្នុងវិសាលភាពនៃរឿងក្តី។ | |
| ៣. | 14-VSS-00017<br>D11/385<br>**ព្រំ សាម៉ុន** | នៅក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់គាត់ ឆ្នាំ២០០៩ អ្នកដាក់ពាក្យសុំបានពិពណ៌នាអំពីពលកម្មដោយបង្ខំ និងលក្ខខណ្ឌរស់នៅអមនុស្សធម៌ចាប់ពីឆ្នាំ១៩៧៥ ឃាតកម្មលើបងប្អូន ០៤នាក់របស់អ្នកដាក់ពាក្យសុំនៅខេត្តកំពត ក្នុងឆ្នាំ១៩៧៦ ការស្លាប់បងប្អូនប្រុសស្រី ឪពុក និងជីតា ដោយសារជំងឺនៅខេត្តកំពត ក្នុងឆ្នាំ១៩៧៧ និងការលង់ទឹកស្លាប់ និងមរណភាពរបស់បងប្អូនប្រុសរបស់អ្នកដាក់ពាក្យសុំម្នាក់ទៀតនៅខេត្តកំពត ក្នុងឆ្នាំ១៩៧៧ ប៉ុន្តែនៅក្នុងទម្រង់បែបបទព័ត៌មានបន្ថែមចុះកាលបរិច្ឆេទឆ្នាំ២០១៣ គាត់បានបញ្ជាក់ថា បងប្រុសស្រី ០៣នាក់ ឪពុក ជីតា ឪពុកមាចំនួន ០៣នាក់ និងម្តាយមីងម្នាក់ | ពាក្យសុំ **មិនអាចទទួលយកបានទេ។** សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**តម្កល់ទុកជាបានការ។** |

| | | | |
|---|---|---|---|
| | | ត្រូវបានបញ្ជូនទៅចម្ការធូរេន ហើយបាត់ខ្លួនពីទីនោះ។ លើសពីនេះទៀត គាត់បាន លើកឡើងអំពីការជម្លៀស និងការដាក់ឲ្យទៅជាទាសករនៅវាម ស្រុកព្រៃនប់។<br><br>ដោយសារភាពមិនស៊ីចង្វាក់គ្នាខ្លាំង ដែលបានកត់សំគាល់រវាង ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ និងទម្រង់បែបបទព័ត៌មានបន្ថែម អ្នកដាក់ពាក្យសុំមិនបានបង្ហាញថា វាមានភាពពិតប្រាកដ ដែលគាត់បានទទួលការឈឺចាប់ដែលជាផលវិបាកនៃឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មជាច្រើន ដែលត្រូវបានចោទប្រកាន់។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុស ដោយសារបដិសេធពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ | |
| ៥. | 14-VSS-00012<br>D11/391<br>**ម៉ៅ សុផល** | អ្នកដាក់ពាក្យសុំបានពិពណ៌នានៅក្នុង ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់គាត់អំពី ការជម្លៀសដោយបង្ខំនៅក្នុងខេត្តកំពត ពលកម្មដោយបង្ខំ និងលក្ខខណ្ឌរស់អមនុស្សធម៌។ គាត់បានបញ្ជាក់ថា ឪពុកមារបស់គាត់ត្រូវបានគេសម្លាប់នៅខេត្តកំពត ក្នុងឆ្នាំ១៩៧៧ ចំណែកនៅក្នុងព័ត៌មានបន្ថែមចុះកាលបរិច្ឆេទឆ្នាំ២០១៣ គាត់បានចោទប្រកាន់ថា ឪពុកមារបស់គាត់ត្រូវបានសម្លាប់នៅចម្ការធូរេនក្នុងខេត្តកំពង់សោម ក្នុងឆ្នាំ១៩៧៨ ហើយគាត់ក៏បានបង្ហាញអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ នៅខេត្តកំពត ក្នុងឆ្នាំ១៩៧៨ នៅក្នុងទម្រង់បែបបទស្តីពីព័ត៌មានបន្ថែម (គាត់មានអាយុ ១២ឆ្នាំ នៅពេលនោះយោងទៅតាមព័ត៌មានអត្តសញ្ញាណរបស់គាត់)។ | ពាក្យសុំ<br>**មិនអាចទទួលយកបានទេ។**<br>សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន<br>**តម្កល់ទុកជាបានការ។** |

| | | | |
|---|---|---|---|
| | | ដោយហេតុថាមានភាពមិនស៊ីសង្វាក់គ្នាខ្លាំង ពាក់ព័ន្ធនឹងតាំងនៃឃាតកម្មលើឪពុកមារបស់គាត់នោះ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធពាក្យសុំនេះ ដោយផ្អែកលើមូលដ្ឋានដែលអ្នកដាក់ពាក្យសុំមិនបានបង្ហាញថា វាមានភាពពិតប្រាកដ ដែលគាត់បានទទួលការឈឺចាប់ដែលជាផលវិបាកនៃឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មជាច្រើន ដែលត្រូវបានចោទប្រកាន់នោះ ពុំមែនមិនសមហេតុផលនោះទេ។ | |
| ៥. | 14-VSS-00016<br>D11/384<br>**អ៊ូច សាគម** | អ្នកដាក់ពាក្យសុំបានពិពណ៌នាដូចតទៅនេះនៅក្នុងពាក្យសុំរបស់គាត់៖ ការដាក់ឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀតប្រឆាំងនឹងអ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់គាត់នៅខេត្តកំពត ក្នុងឆ្នាំ១៩៧៥-១៩៧៦ និងនៅវាលរេញ ខេត្តកំពង់សោម ក្នុងឆ្នាំ១៩៧៧ និងឃាតកម្មលើស្វាមីរបស់អ្នកដាក់ពាក្យសុំ និងបងប្អូនបង្កើតចំនួន ០៤នាក់នៅការដ្ឋានការងារបិតត្រាំង ស្រុកព្រៃនប់ ខេត្តកំពង់សោម ក្នុងឆ្នាំ១៩៧៨។<br><br>មានភាពមិនស៊ីចង្វាក់គ្នាតិចតួច ទាក់ទងនឹងបងប្រុសរបស់គាត់ឈ្មោះ អ៊ូច សឹង៖ បន្ទាប់ពីបានលើកឡើងថា គាត់មានវត្តមាននៅវាលរេញ ក្នុងឆ្នាំ១៩៧៧ ជាមួយសមាជិកដទៃទៀតនៃគ្រួសាររបស់គាត់ គាត់បានបញ្ជាក់ថា សាច់ញាតិម្នាក់របស់គាត់ម្នាក់ដែលបានរួចផុតពីសេចក្ដីស្លាប់ក្នុងរបបនោះបានប្រាប់គាត់ក្នុងឆ្នាំ ១៩៧៩ ថា អ៊ូច សឹង ត្រូវបានសម្លាប់នៅខេត្តតាកែវ ក្នុងឆ្នាំ១៩៧៥។ ភាពមិនស៊ីចង្វាក់គ្នានេះមិនប៉ះពាល់ដល់ភាពជាប់ពាក់ព័ន្ធគ្នា | ពាក្យសុំត្រូវបាន**ទទួលយក**។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន **ច្រានចោល**។ |

| | | | |
|---|---|---|---|
| | | និងភាពគួរឲ្យជឿជាក់បាននៃអង្គហេតុផ្សេងទៀតដែលបានពិពណ៌នាដោយអ្នកដាក់ពាក្យសុំទាក់ទងនឹងបទពិសោធន៍ដែលគាត់ និងសមាជិកគ្រួសារដទៃទៀតបានឆ្លងកាត់នោះទេ។<br><br>ដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា វាមានភាពពិតប្រាកដ ដែលគាត់ និងគ្រួសាររបស់គាត់បានទទួលរងព្យសនកម្ម ដែលស្ថិតក្នុងវិសាលភាពនៃរឿងក្តីបច្ចុប្បន្ន។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយបានបដិសេធពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ | |
| **៦.** | 17-VSS-00043<br>D11/646<br>**អន ដារ៉ាវុត** | អ្នកដាក់ពាក្យសុំបានពិពណ៌នាអំពីការដាក់ឲ្យទៅជាទាសករលើរូបគាត់ និងអំពើអមនុស្សធម៌ផ្សេងៗទៀត នៅស្រុកព្រៃនប់ ខេត្តកំពង់សោម ក្នុងឆ្នាំ១៩៧៥ និងនៅខេត្តកំពង់ឆ្នាំង ពីឆ្នាំ១៩៧៦ រហូតដល់ ឆ្នាំ១៩៧៩ ការដាក់ឲ្យទៅជាទាសករចំពោះម្តាយ និងជីតារបស់អ្នកដាក់ពាក្យសុំនៅឆ្នាំ១៩៧៥ នៅព្រៃនប់ មរណភាពមាតាបងប្អូនស្រីបង្កើត និងជីតារបស់អ្នកដាក់ពាក្យសុំ ដោយសារការអត់ឃ្លានក្នុងឆ្នាំ១៩៧៥-១៩៧៦ ការបាត់ខ្លួនឪពុករបស់អ្នកដាក់ពាក្យសុំ (អតីតទាហាន លន់ ណុល) ក្នុងឆ្នាំ១៩៧៥។<br><br>ក្នុងការអនុវត្តលក្ខខណ្ឌតម្រូវអំពីចំណងទាក់ទងរវាងហេតុ និងផល ដែលពិពណ៌នានៅក្នុងសេចក្តីសម្រេចបច្ចុប្បន្ន ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តចំពោះអ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់គាត់នៅកំពង់សោម ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង។ ដូច្នេះ | ពាក្យសុំត្រូវបាន**ទទួលយក**។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**ច្រានចោល**។ |

| | | | |
|---|---|---|---|
| | | សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយសារបានច្រានចោលពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ | |
| ៧. | 17-VSS-00138<br>D11/256<br>**ឡុង រិន** | អ្នកដាក់ពាក្យបានពិពណ៌នាអំពីអំពើដាក់ឲ្យជាទាសករលើក្រុមគ្រួសារគាត់នៅក្នុងខេត្តកំពង់ចាម នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ អំពើមនុស្សឃាតលើបងប្រុសរបស់គាត់ និងប្រពន្ធកំពុងមានផ្ទៃពោះ ប្រព្រឹត្តដោយទាហានខ្មែរក្រហម ក្រោមការចោទប្រកាន់ថាមិនស្មោះត្រង់នឹងអង្គការ នៅក្នុងខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៧៥ ការចាប់ខ្លួន ការដាក់ពន្ធនាគារ និងអំពើមនុស្សឃាតលើប្អូនប្រុសរបស់គាត់ឈ្មោះ សំ ឈឿន នៅគុកទួលស្លែង ក្នុងឆ្នាំ១៩៧៧។ យោងតាមឯកសារ ដែលបានដាក់នៅក្នុងទម្រង់បែបបទស្តីពីព័ត៌មានបន្ថែមរបស់គាត់ សំ ឈឿន គឺជាលេខាកងពល ៣១០ ។<br><br>ទោះបីសង្កេតឃើញភាពមិនស៊ីចង្វាក់គ្នាតិចតួចនៅក្នុង VIF និងទម្រង់បែបបទព័ត៌មានបន្ថែមរបស់អ្នកដាក់ពាក្យសុំក៏ដោយ (អ្នកដាក់ពាក្យសុំបានលើកឡើងថា បងប្រុសរបស់គាត់ឈ្មោះ ឡុង ឬ សំ ឈឿន និងជាប្អូនប្រុស ឬបងប្រុសរបស់គាត់) ចៅក្រមអន្តរជាតិកត់សម្គាល់ថា វាពុំប៉ះពាល់ដល់ភាពពាក់ព័ន្ធ និងភាពជឿជាក់បាននៃអង្គហេតុផ្សេងទៀត ដែលអ្នកដាក់ | ពាក្យសុំត្រូវបាន**ទទួលយក**។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**ច្រានចោល**។ |

| | | | |
|---|---|---|---|
| | | ពាក្យសុំបានពិពណ៌នាទាក់ទងទៅនឹងបទពិសោធន៍ ដែលគាត់និងសមាជិកគ្រួសារដទៃទៀតបានឆ្លងកាត់នោះឡើយ។<br><br>ដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា ព្រឹត្តិការណ៍ដែលទាក់ទងទៅនឹងបងប្អូនប្រុសរបស់អ្នកដាក់ពាក្យសុំ ត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការបោសសំអាតកងពល ៣១០ ហើយស្ថិតក្នុងវិសាលភាពនៃរឿងក្តីនេះ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ | |
| ៨. | 11-VSS-00293<br>D11/95<br>**វង់ គីមសួន** | អ្នកដាក់ពាក្យសុំ អតីតទាហាន លន់ នល់ បានរៀបរាប់អំពីការជម្លៀសដោយបង្ខំពីភ្នំពេញទៅក្តីតាកុយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ការដាក់ឲ្យជាទាសករនៅក្នុងក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៥ ការដាក់ឲ្យទៅជាទាសករនៅកំពង់សោម នៅឆ្នាំ១៩៧៥ ការដាក់ឲ្យទៅជាទាសករ និងការបង្អត់អាហារ នៅស្រុកឆែប ខេត្តព្រះវិហារ នៅខែមិថុនា ឆ្នាំ១៩៧៥ ការផ្លាស់ទីលំនៅ និងការសម្លាប់បងប្អូនជីដូនមួយម្នាក់ និងក្រុមគ្រួសាររបស់គាត់នៅខេត្តកំពង់ស្ពឺ ក្នុងឆ្នាំ១៩៧៥ ការផ្លាស់ទីលំនៅដោយបង្ខំនិងការបាត់ខ្លួនបងប្អូនជីដូនមួយពីរនាក់ និងគ្រួសាររបស់ពួកគេ (មិនបានបញ្ជាក់ទីតាំង) នៅឆ្នាំ ១៩៧៥ ការដាក់ឲ្យទៅជាទាសករនៅសាអែម (ទីតាំងមិនច្បាស់) ក្នុងឆ្នាំ១៩៧៨។ | ពាក្យសុំត្រូវបាន**ទទួលយក**។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបាន**ច្រានចោល**។ |

| | | | |
|---|---|---|---|
| | | អ្នកដាក់ពាក្យសុំ ត្រូវបានបង្ខំឱ្យធ្វើការជាអ្នកបើកបរ នៅក្នុងឆ្នាំ១៩៧៥ ក្នុងអំឡុងពេលដែលគាត់ត្រូវបានគេបញ្ជាឱ្យដឹកម្ហូបអាហារពីភ្នំពេញទៅកំពង់សោមជាកន្លែងដែលគាត់ស្នាក់នៅទីនោះរយៈពេលពីរខែ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយសារបានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ដោយផ្អែកលើមូលហេតុដែលថា ព្រឹត្តិការណ៍ដូចបានពិពណ៌នាមិនស្ថិតនៅក្នុងវិសាលភាពនៃរឿងក្តី។ | |